# ធម្មទេសនារបស់លោកអភិបាល អូលីវីយេ៉
## អភិបូជាសប្ដាហ៍ទី៤នៃរដូវរង់ចាំ នៅព្រះសហគមន៍សន្តីម៉ារីញញឹម
## ចំការទៀន ថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២០
## ខ្ញុំជាអ្នកបម្រើរបស់ព្រះអម្ចាស់

**អត្ថបទទី១៖ សាមូអែលទី២ ៧,១-៥.៨ខ-១២.១៤ក.១៦**

«សូមលោកគិតមើល ខ្ញុំរស់នៅក្នុងដំណាក់ធ្វើអំពីឈើដ៏មានតម្លៃ រីឯហិបនៃព្រះជាម្ចាស់ស្ថិតនៅក្នុងព្រះពន្លាធ្វើអំពីក្រណាត់សំពត់!»។ ២សម ៧,

**អត្ថបទទី២៖ រ៉ូម ១៦,២៥-២៧**

សូមលើកតម្កើងសិរីរុងរឿងរបស់ព្រះអង្គ តាមរយៈព្រះយេស៊ូគ្រីស្តអស់កល្បជាអង្វែងតរៀងទៅ។ រម ១៦,២៧

**ដំណឹងល្អ៖ លូកា ១,២៦-៣៨**

«ចូរមានអំណរសប្បាយឡើង! ព្រះអម្ចាស់គាប់ព្រះហឫទ័យនឹងនាងហើយ ព្រះអង្គគង់ជាមួយនាង»។ លក ១,២៨

បងប្អូនជាទីស្រឡាញ់!

យើងដល់សប្ដាហ៍ទី៤នៃរដូវរង់ចាំ ជិតដល់ពេលវេលាដែលព្រះយេស៊ូប្រសូតនៅក្នុងពិភពលោកនេះ។ ជិតដល់ពេលវេលា ដែលយើងត្រូវតែទទួលស្វាគមន៍ព្រះពន្លឺរបស់ព្រះអង្គនៅក្នុងភាពងងឹតនៃជីវិត ដើម្បីឲ្យពន្លឺនេះបំភ្លឺជីវិតរបស់យើងផ្ទាល់។ នៅពេលព្រះនាងម៉ារីបានទទួលដំណឹងពីទេវទូតកាព្រីអែល ដូចយើងបានស្ដាប់ថ្ងៃនេះក្នុងគម្ពីរដំណឹងល្អ។ ដំបូងព្រះនាងម៉ារីគាត់ឆ្ងល់ រំភើប គាត់បានសួរថា "**ធ្វើដូចម្ដេចឲ្យហេតុការណ៍នេះកើតឡើងបាន?**"។ ប៉ុន្តែ ព្រះវិញ្ញាណដ៏វិសុទ្ធគង់នៅជាមួយព្រះនាងម៉ារី ដើម្បីឲ្យព្រះនាងម៉ារីទៅជាម្ដាយរបស់ព្រះយេស៊ូ មានន័យថាឲ្យផ្ទៃពោះរបស់ព្រះនាងម៉ារីទៅជាព្រះដំណាក់យ៉ាងពិសេស ដើម្បីទទួលស្វាគមន៍ព្រះជាម្ចាស់។

យើងបានស្ដាប់នៅក្នុងអត្ថបទទីមួយថា "**សូមគិតមើលទៅ យើងរស់នៅក្នុងដំណាក់ធ្វើអំពីឈើដ៏មានតម្លៃណាស់ រីឯហិបនៃព្រះជាម្ចាស់ស្ថិតនៅក្នុងពន្លាធ្វើអំពីក្រណាត់សំពត់**"។ គេកំពុងឆ្ងល់ ស្ដេចរស់នៅក្នុងផ្ទះឈើដ៏មានតម្លៃ ប៉ុន្តែព្រះជាម្ចាស់ផ្ទាល់នៅក្នុងព្រះពន្លាមួយធ្វើអំពីក្រណាត់សំពត់ដែលថោកបំផុត។ **តើនេះគួរសមឬអត់?** ថ្ងៃនេះដែលយើងបានស្ដាប់គម្ពីរដំណឹងល្អអំពីព្រះនាងម៉ារីទទួលដំណឹងពីទេវទូតកាព្រីអែល យើងឃើញព្រះនាងម៉ារីទៅជាព្រះដំណាក់សម្រាប់ទទួលស្វាគមន៍ព្រះយេស៊ូដែលកំពុងយាងមក។ ព្រះជាម្ចាស់បានរើសព្រះនាងម៉ារីដែលគ្មានជំពាក់បាប ព្រះជាម្ចាស់បានជ្រើសរើសព្រះនាងម៉ារីដែលជាព្រហ្មចារីនីដ៏វិសុទ្ធ ដើម្បីទៅជា

ព្រះពន្លា ដើម្បីទៅជាព្រះដំណាក់មួយយ៉ាងពិសេស ក្នុងការទទួលស្វាគមន៍ព្រះយេស៊ូនៅក្នុងពិភពលោកនេះ។

ថ្ងៃនេះជាពេលវេលាដើម្បីគិតពិចារណា **តើយើងដែលជាគ្រីស្តបរិស័ទ យើងបានរៀបចំអ្វីខ្លះដើម្បីទទួលស្វាគមន៍ព្រះជាម្ចាស់?** ព្រះជាម្ចាស់មិនត្រូវការមានផ្ទះឈើដ៏មានតម្លៃ ព្រះជាម្ចាស់មិនត្រូវការមានកន្លែងមួយធ្វើដោយថ្មយ៉ាងស្អាតបំផុត។ ប៉ុន្តែ ព្រះជាម្ចាស់ត្រូវតែទទួលបានមនុស្សម្នាក់ដែលមានចិត្តគំនិតពោរពេញដោយសេចក្តីស្រឡាញ់ ដែលមានអំណរសប្បាយដូចព្រះនាងម៉ារី។ ព្រះនាងម៉ារីពីដើម បានទទួលស្វាគមន៍ព្រះយេស៊ូនៅក្នុងដួងចិត្ត នៅក្នុងផ្ទៃពោះរបស់ព្រះនាង នៅក្នុងអំណរសប្បាយ នៅក្នុងសេចក្តីស្រឡាញ់ នៅក្នុងចិត្តបរិសុទ្ធ។ ធ្វើតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់ ដោយនិយាយថា "**នាងខ្ញុំជាអ្នកបម្រើព្រះជាម្ចាស់ពិតមែន**" នេះជាអ្វីដែលព្រះជាម្ចាស់ទន្ទឹងរង់ចាំ។

នៅក្នុងព្រះវិហារនីមួយៗនៃភូមិភាគភ្នំពេញ ទោះបីយើងអាចជួបជុំគ្នាយ៉ាងតិចក៏ដោយ ខ្ញុំបានអញ្ជើញឲ្យគ្រីស្តបរិស័ទ គណៈកម្មការ បងប្រុសបងស្រី លោកបូជាចារ្យ យកចិត្តទុកដាក់ដើម្បីរៀបចំកន្លែងយ៉ាងស្អាតបំផុត ដើម្បីបង្ហាញថាពិតមែនយើងមានអំណរសប្បាយ ពិតមែនយើងសប្បាយចិត្ត។ ទោះបីយើងអាចជួបជុំគ្នាតិចក៏ដោយ យើងមិនអាចប្រមូលមនុស្សរាប់ពាន់នាក់ដូចរាល់ឆ្នាំ ដោយសារជំងឺកូវីដ-១៩។ ប៉ុន្តែ យើងដឹងថាអំណរសប្បាយត្រូវតែស្ថិតស្ថេរ ការស្វាគមន៍ព្រះយេស៊ូត្រូវការរាក់ទាក់បំផុត។ នៅក្នុងភាពងងឹតក៏ដោយ អំណរសប្បាយក៏ដោយព្រះយេស៊ូយាងមក យើងត្រូវការរៀបចំចិត្តគំនិត។ ថ្ងៃនេះយើងមានច្រើនដំណាក់កាល ក្នុងការរៀបចំស្វាគមន៍ព្រះយេស៊ូ។

ស្វាគមន៍ព្រះយេស៊ូនៅក្នុងដួងចិត្តរបស់យើង ដើម្បីឲ្យទៅជាព្រះពន្លាមួយដ៏មានតម្លៃបំផុត ដោយសារជាព្រះពន្លាដ៏មានជីវិត។ ជាព្រះពន្លាធ្វើដោយឈាម ធ្វើដោយសាច់ ធ្វើដោយញើស ធ្វើដោយកម្លាំង ធ្វើដោយសេចក្តីស្រឡាញ់ ធ្វើដោយចិត្តគំនិតដែលចេញពីដួងចិត្តរបស់យើង។ ប្រសិនបើបងប្អូនស្តាប់អត្ថបទទីមួយសាជាថ្មី រឿងព្រះពន្លារៀបចំដោយក្រណាត់សំពត់មួយ ឬរៀបចំដោយឈើដែលមានតម្លៃមិនសំខាន់ទេ។ អ្វីដែលសំខាន់បំផុត គឺជាព្រះបន្ទូលរបស់ព្រះជាម្ចាស់នៅក្នុងអត្ថបទទីមួយ គឺព្រះជាម្ចាស់មានវត្តមាននៅក្នុងប្រជារាស្ត្ររបស់ព្រះអង្គ។ ព្រះជាម្ចាស់ដែលជ្រើសរើសទីតាំងដើម្បីនៅ គឺព្រះជាម្ចាស់ដែលមានព្រះបន្ទូលថា "**យើងស្ថិតនៅជាមួយអ្នកគ្រប់ទីកន្លែងដែលអ្នកទៅ**"។ ពេលយើងស្តាប់នេះហើយ យើងយល់ហើយថាវត្តមានរបស់ព្រះជាម្ចាស់នៅក្នុងដួងចិត្តរបស់យើង កន្លែងណាដែលយើងនៅព្រះជាម្ចាស់គង់នៅ កន្លែងណាដែលយើងទៅព្រះជាម្ចាស់ទៅដែរ។ មានន័យថា ទាំងនៅក្នុងទុក្ខលំបាក ទាំងនៅក្នុងអំណរ

ទាំងនៅក្នុងពេលវេលាដែលយើងមានសេចក្ដីសង្ឃឹម ទាំងនៅក្នុងពេលវេលាដែលយើងអស់សង្ឃឹម ទាំងនៅក្នុងវដ្ដូវកូវីដ-១៩នេះ យើងត្រូវតែមានគំនិតថ្មីៗដើម្បីស្វាគមន៍ព្រះយេស៊ូ ដោយសារកន្លែងដែលយើងនៅ យើងដឹងថាព្រះជាម្ចាស់គង់នៅ។ នេះជាអ្វីដែលព្រះនាងម៉ារី បានយល់ភ្លាម ពេលទេវទូតកាព្រីអែលមកសួរសុខទុក្ខព្រះនាងម៉ារី ដើម្បីប្រាប់ព័ត៌មានយ៉ាងពិសេសទៅព្រះនាងម៉ារី ទៅជាមាតារបស់ព្រះជាម្ចាស់ ណែនាំឲ្យព្រះនាងម៉ារីឆ្លើយភ្លាមៗថា "**នាងខ្ញុំជាអ្នកបម្រើរបស់ព្រះជាម្ចាស់**"។ ដោយសារ ព្រះនាងម៉ារីបានយល់ព្រះជាម្ចាស់បានជ្រើសរើសគាត់ "**ព្រះវិញ្ញាណដ៏វិសុទ្ធនឹងយាងមកសណ្ឋិតលើនាង គឺឫទ្ធានុភាពរបស់ព្រះដ៏ខ្ពង់ខ្ពស់បំផុតនឹងគ្របបាំងនាង**"។ ព្រះនាងម៉ារី យល់នៅក្នុងអាថ៌កំបាំងដ៏អស្ចារ្យដែលព្រះជាម្ចាស់បានរៀបចំហើយ ប៉ុន្តែព្រះនាងម៉ារីស្វាគមន៍ព្រះយេស៊ូភ្លាមដោយយល់ថា គាត់ទៅជាព្រះដំណាក់របស់ព្រះដ៏មានជីវិត ដើម្បីធ្វើដំណើរនៅក្នុងលោកនេះ និងដើម្បីណែនាំឲ្យព្រះយេស៊ូមានទីលំនៅនៅក្នុងពិភពលោកនេះ។

ដូច្នេះ ថ្ងៃនេះខ្ញុំសូមអញ្ជើញព្រះសហគមន៍នីមួយៗនៅក្នុងភូមិភាគភ្នំពេញ ឲ្យយកចិត្តទុកដាក់ទៅជាព្រះពន្លាមួយដ៏ពិសេស ទៅជាព្រះដំណាក់មួយដ៏ពិសេស ស្អាតបំផុតដើម្បីស្វាគមន៍ព្រះយេស៊ូដែលយាងមក ឲ្យបប់បុណ្យព្រះយេស៊ូប្រសូតទោះបីមានគ្នាតិចក៏ដោយ យើងដឹងថាព្រះយេស៊ូមានកន្លែងមួយដើម្បីប្រសូត ដើម្បីនៅ។ យើងនឹកឃើញ ពេលព្រះយេស៊ូប្រសូតនៅភូមិបេថ្លេហឹម នៅពេលនោះផ្ទះសំណាក់ពេញអស់ហើយ មណ្ឌលសុខភាពឥតមានទេ។ ប៉ុន្តែលោកយ៉ូសែបបានរកឃើញកន្លែងមួយគឺក្រោលគោ ទីកន្លែងមិនសំខាន់ទេអ្វីដែលសំខាន់គឺវត្តមានរបស់ម្ដាយ វត្តមានរបស់ឪពុក ប្រជារាស្ត្រដែលមកថ្វាយបង្គំ។ មានហោរាចារ្យ គ្រូគង្វាល ប្រជាជនមួយចំនួនដែលមកថ្វាយបង្គំដល់ព្រះយេស៊ូដែលប្រសូតហើយ នេះជាអ្វីដែលសំខាន់បំផុត។ ទីកន្លែងស្អាតឬមិនស្អាតមិនសំខាន់ទេ ដោយសារកន្លែងស្អាតលុះត្រាតែយើងរាក់ទាក់ស្វាគមន៍នៅក្នុងសេចក្ដីស្រឡាញ់។

យើងបានឃើញ នៅតាមផ្ទះនីមួយៗព្រឹកឡើងយើងបោសសំរាម ដើម្បីឲ្យផ្ទះរបស់យើងស្អាតក្នុងការស្វាគមន៍ភ្ញៀវ។ ជាផ្ទះឈើក៏ដោយ ជាផ្ទះថ្មក៏ដោយ ជាផ្ទះធ្វើពីស័ង្កសីក៏ដោយ សំខាន់គឺរបៀបដែលយើងរៀបចំផ្ទះរបស់យើង របៀបដែលយើងរៀបចំអនាម័យ របៀបដែលយើងស្វាគមន៍ភ្ញៀវ របៀបដែលយើងរាក់ទាក់បងប្អូនដែលធ្វើដំណើរតាមផ្លូវ... នេះជាអ្វីដែលសំខាន់បំផុត។ លោកអាប្រាហាំ នៅពេលគាត់មានភ្ញៀវបីអ្នកដែលកំពុងធ្វើដំណើរ លោកអាប្រាហាំបានឃើញគេពីចម្ងាយហើយអញ្ជើញគេមកអង្គុយលេងជាមួយគាត់។ នៅពេលហ្នឹង លោកអាប្រាហាំបានទទួលដំណឹងថាប្រពន្ធគាត់មានផ្ទៃពោះ ជាដំណឹងដែលគាត់ទន្ទឹងរង់ចាំពីយូរមក

ហើយ។ ដោយសារលោកអាប្រាហាំបានទទួលស្វាគមន៍ភ្ញៀវបីនាក់ បីដូចជាព្រះជាម្ចាស់ផ្ទាល់ ដែលយាងមកសួរសុខទុក្ខលោកអាប្រាហាំ។ ដូច្នេះ យើងដឹងថាព្រះយេស៊ូយាងមកនៅយប់បុណ្យព្រះយេស៊ូប្រសូតមែន ប៉ុន្តែព្រះយេស៊ូកំពុងយាងមកជារៀងរាល់ថ្ងៃ។ ពីមួយថ្ងៃទៅមួយថ្ងៃ យើងបានជួបមនុស្សម្នាក់អាចជាព្រះយេស៊ូដែលកំពុងសួរសុខទុក្ខយើង យើងបានជួបបងប្អូនដែលគ្មានសេចក្តីសង្ឃឹម ប៉ុន្តែជាវត្តមានរបស់ព្រះយេស៊ូដែលកំពុងយាងមកដើម្បីសួរសុខទុក្ខយើងដែរ។ **តើយើងអាចទទួលស្វាគមន៍គេដែរ? តើយើងបានរៀបចំចិត្តគំនិតដើម្បីរាក់ទាក់ដល់មនុស្សទាំងអស់ ជាពិសេសមនុស្សដែលគ្មានសេចក្តីសង្ឃឹម? តើយើងបានយកចិត្តទុកដាក់ដើម្បីឲ្យព្រះពន្លាដែលយើងមាននៅក្នុងដួងចិត្តរបស់យើង ទៅជាកន្លែងមួយយ៉ាងស្អាតបំផុតសម្រាប់ស្វាគមន៍ជានិច្ចនៅក្នុងការរាក់ទាក់?**

ដូច្នេះ ថ្ងៃនេះសូមព្រះជាម្ចាស់ជួយយើង ដើម្បីឲ្យព្រះសហគមន៍របស់យើងនៅក្នុងស្ថានភាពដែលយើងមានសព្វថ្ងៃ ណែនាំឲ្យយើងយល់ថាយើងជាព្រះដំណាក់របស់ព្រះយេស៊ូយ៉ាងពិសេស។ កន្លែងណាដែលយើងនៅកន្លែងហ្នឹងព្រះជាម្ចាស់គង់នៅ កន្លែងណាដែលយើងទៅកន្លែងហ្នឹងព្រះជាម្ចាស់ទៅដែរ។ នៅថ្ងៃដែលព្រះយេស៊ូប្រសូត ឲ្យព្រះវិហាររបស់យើង ឲ្យជីវិតរបស់យើងផ្ទាល់ ទៅជាទីលំនៅមួយយ៉ាងពិសេសដើម្បីស្វាគមន៍ព្រះយេស៊ូ។ ដោយដឹងថា ព្រះយេស៊ូយាងមកតាមរយៈបងប្អូនឯទៀតៗ តាមរយៈអ្នកជំងឺ អ្នកក្រីក្រ ចាស់ជរា កូនក្មេង អ្នកមានពិការភាព បងប្អូនដែលគ្មានទីពឹង... ព្រះយេស៊ូយាងមកតាមរយៈពួកគាត់ដែរ។

យើងអធិដ្ឋាន ដើម្បីឲ្យចិត្តគំនិតរបស់យើងទៅជាចិត្តគំនិតយ៉ាងស្អាតបំផុត ដូចព្រះនាងម៉ារីពីដើម ហើយយើងហ៊ានឆ្លើយអស់ពីដួងចិត្តថា "**ខ្ញុំជាអ្នកបម្រើរបស់ព្រះជាម្ចាស់ សូមធ្វើតាមព្រះហឫទ័យរបស់ព្រះអង្គចុះ**"។ អាម៉ែន៕